01714627

F78

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Nov-22, 08:00
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

ផ្ញើពី: ប្រធានអង្គជំនុំជម្រះតុលាការកំពូល
("ប្រធាន")
**President of the Supreme Court Chamber**
**(the "President")**

ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២២

ផ្ញើជូន: ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្ដីទី
លោក **Knut Rosandhaug** អនុប្រធានការិយាល័យរដ្ឋបាល
**H.E. Mr. Tony KRANH**, Acting Director of Administration
**Mr. Knut ROSANDHAUG**, Deputy Director of Administration

ចម្លងជូន ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល
ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល
លោក ពេជ អង្គ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
លោកស្រី **Falguni DEBNATH** សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
**Judges of the Supreme Court Chamber**
**Greffiers of the Supreme Court Chamber**
**Mr. PICH Ang, Civil Party Lead Co-Lawyer**
**Ms. Falguni DEBNATH, Civil Party Lead Co-Lawyer**

កម្មវត្ថុ ការឆ្លើយតបទៅនឹងអនុស្សរណៈរបស់ការិយាល័យរដ្ឋបាលពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារទៅភាគីទីបី ឬភាគីដទៃទៀត ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២
Response to the Office of Administration's Memorandum concerning the Disclosure of Documents to Third Party or Parties" dated 17 October 2022

នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានទទួលអនុស្សរណៈផ្ញើពីប្រធាន និងអនុប្រធាននៃការិយាល័យរដ្ឋបាលជូនដំណឹងដល់អង្គជំនុំជម្រះថា ឯកសាររបស់តុលាការប្រមាណ ១.៤០០ ច្បាប់ ត្រូវបាន"បរិច្ចាគ"ទៅឱ្យភាគីទីបីតាមរយៈលោកស្រី Martine JACQUIN ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៃក្រុមដើមបណ្ដឹងរដ្ឋប្បវេណី DFS។ ពុំមានការបង្ហាញច្បាស់លាស់ថាតើ

ឯកសារនោះ មានលក្ខណៈប៉ះពាល់ ឬត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់ដោយតុលាការ ដែរ ឬយ៉ាងណាឡើយ។

ជាការឆ្លើយតប សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជូនអនុស្សរណៈចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២២ ដោយជម្រាបអង្គជំនុំជម្រះអំពីវិធានការដែលបានធ្វើឡើងលើបញ្ហានេះនៅមុនការបង្ហាញឯកសារនេះដល់ភាគីទីបី។ សហមេធាវីនាំមុខបានជូនដំណឹងអង្គជំនុំជម្រះថា បន្ទាប់ពីការប្រកាសសាលដីកាសំណុំរឿង ០០២/០២ កិច្ចប្រជុំមួយត្រូវបានធ្វើឡើងជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលក្នុងនោះលោកស្រី Martine JACQUIN បានលើកបញ្ហានៃការផ្តល់ឯកសារដើមបណ្តឹងរដ្ឋប្បវេណីទៅឱ្យភាគីទីបី ហើយគាត់ត្រូវបានផ្តល់យោបល់ថា ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីពុំគប្បីត្រូវផ្តល់ទៅឱ្យភាគីទីបីដោយគ្មានការយល់ព្រមពីដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ បន្ទាប់ពីមានព័ត៌មានចុះផ្សាយអំពី“ការបរិច្ចាគ”ឯកសារ ១.៤០០ ច្បាប់ទៅឱ្យភាគីទីបី សហមេធាវីនាំមុខបានផ្ញើលិខិតមួយទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២២ រំឭកពួកគាត់អំពីកាតព្វកិច្ចវិជ្ជាជីវៈរក្សាការសម្ងាត់កូនក្តីរបស់ខ្លួន ព្រមទាំងកាតព្វកិច្ចចំពោះគណៈមេធាវីកម្ពុជា។ លោកស្រី Martine JACQUIN បានឆ្លើយតបតាមរយៈអ៊ីមែលថា “ឯកសារនោះទាំងនោះពិតប្រាកដណាស់ត្រូវបានរក្សាទុកក្នុងប័ណ្ណសារ និងសម្រាប់ការប្រើប្រាស់របស់គ្រួសារពួកគេ។ តុលាការពុំបានទទួលយកឯកសារនេះទុកក្នុងកំណត់ត្រារបស់តុលាការឡើយ។ នេះគឺជាឯកសារប្រវត្តិសាស្ត្រ និងជាកំណត់ត្រាផ្ទាល់ខ្លួននៃក្រុមគ្រួសារដែលពាក់ព័ន្ធ។ ឯកសារទាំងនេះពុំគប្បីធ្វើឱ្យបាត់បង់ ឬរប៉ាត់រប៉ាយឡើយ។ ក្រុមគ្រួសារអាចទទួលបានឯកសារនេះនៅពេលណាដែលពួកគេត្រូវការ”។

ផ្អែកលើព័ត៌មានខាងលើ និងការរំឭកអំពីបទប្បញ្ញត្តិនៃវិធាន ២២ និងជាពិសេសវិធាន ២២ (៣) នៃវិធានផ្ទៃក្នុងចែងថា “រាល់ការទំនាក់ទំនងទាំងអស់រវាងមេធាវី និងកូនក្តីរបស់ពួកគេ ត្រូវរក្សាការសម្ងាត់ ហើយមិនត្រូវមានការលួចស្តាប់ ឬថត ឬថតចម្លងដោយជនផ្សេងឡើយ”។ បន្ថែមលើនេះ មេធាវីទាំងអស់នៅចំពោះមុខ អ.វ.ត.ក. ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់កូនក្តីរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៩ នៃក្រមវិជ្ជាជីវៈមេធាវីនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា។ ការរំលោភបំពានណាមួយលើកាតព្វកិច្ចទាំងនេះអាចជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការស្របតាមមាត្រា ៣៥ នៃវិធានផ្ទៃក្នុង។

ប្រធានអង្គជំនុំជម្រះតុលាការកំពូលពិនិត្យឃើញថា អង្គជំនុំជម្រះនៅពុំទាន់បានសម្រេចលើការដាក់ចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងនោះទៅឡើយ និងរំឭកថា ការសង្កេតរបស់សហមេធាវីនាំមុខ*ក្នុងចំណោមនោះ*បានបញ្ជាក់នូវសារៈសំខាន់នៃការរក្សាការសម្ងាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

អាស្រ័យហេតុនេះ ប្រធានអង្គជំនុំជម្រះបង្គាប់ការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីឱ្យទំនាក់ទំនងជាមួយលោកស្រី Martine JACQUIN ដើម្បីកំណត់៖ (១) ថាតើ មានដីកាបង្គាប់របស់តុលាការណាខ្លះត្រូវបានចេញដែលអនុញ្ញាតឱ្យលោកស្រី JACQUIN បង្ហាញឯកសារទៅភាគីទីបីដែរ ឬទេ (២) ថាតើ មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកូនក្តីនោះ ដែរ ឬទេ ប្រសិនបើមាន ត្រូវផ្តល់ច្បាប់ចម្លងនៃការយល់ព្រមនោះ (៣) ត្រូវធានាថា រាល់ឯកសារទាំងនោះត្រូវប្រគល់ត្រឡប់មក អ.វ.ត.ក. វិញ (៤) ត្រូវពិនិត្យច្បាស់លាស់ និងចងក្រងតាមប្រភេទឯកសារត្រឹមត្រូវ (៥) និងរាយការណ៍ជូនប្រធានអង្គជំនុំជម្រះនូវបញ្ជីឈ្មោះឯកសារដែលបានដាក់តាមប្រភេទនោះ និងលិខិតយល់ព្រមណាខ្លះប្រសិនបើមាន។

The President received a Memorandum from the Acting and Deputy Directors of the Office of Administration dated 17 October 2022, informing him and the Chamber that judicial documents, approximately 1,400 documents were “donated” to a third party, by Ms. Martine JACQUIN, a civil party lawyer on the DFS Civil Party Team. It is unclear whether the documents are sensitive in nature or judicially classified as confidential.

In response, the Civil Party Lead Co-Lawyers transmitted a Memorandum dated 28 October 2022, advising the Chamber of the steps taken in this matter prior to the disclosure of documents to a third party. They informed the Chamber that, following the pronouncement of the Appeal judgment in Case 002/02, a meeting with several civil party lawyers was convened, during which Ms. JACQUIN raised the issue of handing civil party documents to a third party and was advised that civil party documents could not be disclosed to a third party without the consent of the Civil Parties. Following the news of the “donation” of 14,00 documents to a third party, the Lead Co-lawyers sent a letter to Civil Party lawyers on 12 October 2022, reminding them of their professional obligation to maintain confidentiality to their clients as well as their obligations to the Bar Association of Cambodia. Ms. JACQUIN responded via email correspondence that “[t]he documents are definitively archived and saved at the disposal of the families. The court did not accept them in the court records. These are historical documents and the memoirs of the families concerned. They should neither disappear nor be dispersed. Families can pick them up whenever they want”.

Both the Office of Administration and the Lead Co-Lawyers have indicated their availability to assist the Chamber in this matter.

Based on the foregoing information and recalling the provisions of Internal Rule 22 and in particular sub-section (3), "all communication between lawyers and their clients shall be confidential and shall not be listened to, recorded or copied by others". Furthermore, all lawyers appearing before the ECCC have a duty to maintain confidentiality towards their clients in accordance with provisions of Article 19 of the *Cambodia's Code of Ethics for Lawyers of the Bar Association of the Kingdom of Cambodia* and Article 58 of the *Law on the Bar*. Any violations of such obligations may constitute interference with the administration of justice under Internal Rule 35.

The President is mindful that the Chamber has yet to rule on the reclassification of documents and recalls that the Lead Co-Lawyers' observations have *inter alia* emphasised the importance of maintaining the confidentiality of the Civil Parties.

Accordingly, the President directs the Office of Administration and the Civil Party Lead Co-Lawyers to liaise with Ms. JACQUIN to determine the following: (1) whether any court order was issued to permit her to disclose the documents to a third party; (2) whether written consent was obtained from the clients, and if so, a copy of each consent be provided; (3) ensure that all the documents in question are retrieved and returned to the ECCC premises; (4) carefully inspect and catalogues all the documents; (5) and report to the President with a full list of the catalogued documents and consent letters, if any.